# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ.....០៤.....សជណ

## សេចក្តីអំពាវនាវ

### របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការស្តារ និងរៀបចំកំណាត់ដងស្ទឹងសៀមរាប

-ព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ ជាទីសក្ការៈ

-បងប្អូនអាជីវករ ពាណិជ្ជករ សេវាករ និង បងប្អូនប្រជាពលរដ្ឋទាំងអស់ជាទីគោរពស្រឡាញ់ !

វិស័យទេសចរណ៍កម្ពុជា គឺជាវិស័យអាទិភាព១ ក្នុងចំណោមវិស័យទាំង៦ សំរាប់ស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ ។ ជារៀងរាល់ឆ្នាំភ្ញៀវទេសចរ ដែលបានចូលមកទស្សនាកម្ពុជា មានការកើនឡើងជាលំដាប់ក្នុងចន្លោះពី ២៥ទៅ៣០% ហើយតាមការប៉ាន់ស្មានរបស់យើងក្នុងឆ្នាំ ២០០៣ ខាងមុខចំនួនភ្ញៀវទេសចរមកទស្សនាកម្ពុជាអាចនឹងកើនដល់ ១លាន នាក់ ហើយអាចនៅក្នុងអំឡុងឆ្នាំ ២០០៥ ខាងមុខ ភ្ញៀវទេសចរដែលមកទស្សនា **តំបន់ទេសចរណ៍សៀមរាបអង្គរ** អាចនឹងកើនដល់ ១លាន នាក់ ឬច្រើនជាងនេះ ។ ទន្ទឹមនឹងនោះ ចំនួនប្រជាពលរដ្ឋយើងក្នុងស្រុក ដែលធ្វើដំណើរកំសាន្តមកកាន់តំបន់នេះ ក៏កាន់តែមានការកើនឡើងយ៉ាងច្រើន ។ ទាំងអស់នេះបានបង្ហាញយ៉ាងច្បាស់ថា សន្តិភាព និងសន្តិសុខ បាន និងកំពុង គ្របដណ្តប់ទូទាំងប្រទេស ។ រាជរដ្ឋាភិបាលកម្ពុជា ដែលមានរូបខ្ញុំជាប្រមុខ នឹងខិតខំប្តូរផ្តាច់ ធ្វើអ្វី១គ្រប់ បែបយ៉ាងដើម្បីថែរក្សាស្ថេរភាព សន្តិភាព សន្តិសុខ ឱ្យបានជារៀងរហូត ដើម្បីជាមូលដ្ឋានដល់ការអភិវឌ្ឍន៍ប្រទេសជាតិ និងជីវភាពរស់នៅដ៏សុខសាន្តរបស់ ប្រជាពលរដ្ឋ ។

ក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងមក រាជរដ្ឋាភិបាល និងខ្លួនខ្ញុំផ្ទាល់បានខិតខំអស់ពីកំលាំងកាយចិត្ត ដើម្បីធ្វើការស្តារហេដ្ឋារចនាសម្ព័ន្ធមានជាអាទិ៍ ប្រព័ន្ធគមនាគមន៍ ស្ពាន ថ្នល់ អាកាសយានដ្ឋាន កំពង់ផែ ។ល។ ដោយឡែក នៅទីក្រុងសៀមរាបអង្គរនេះ អាកាសយានដ្ឋានកំពុងបន្តស្តារ• និង អភិវឌ្ឍន៍ទៅមុខជានិច្ច ដើម្បីបញ្ចប់ដំណាក់កាលទី១ ក្នុងចំណោមដំណាក់កាលទាំង៤ ផ្លូវថ្នល់ក្នុងក្រុងបានស្តារ និងជួសជុលជាបន្តបន្ទាប់ ផ្លូវថ្នល់ទៅភ្នំក្រោមក៏កំពុងស្តារ និងស្ថាបនា ភ្លើងអគ្គិសនីបំភ្លឺផ្លូវក៏នឹងរៀបចំដាក់ជាបណ្តើរ១ ។ល។ ក្នុងនោះដងស្ទឹងសៀមរាប ដែលកាលពីប្រវត្តិសាស្ត្រដ៏យូរលង់គឺ ជាផ្លូវទឹកយ៉ាងសំខាន់បំរើឱ្យការដឹកជញ្ជូនថ្មសិលាមកកសាងប្រាសាទនានានៅតំបន់អង្គរនោះ ក៏បានស្ថិតក្នុងផែនការស្តារ និងរៀបចំឡើងវិញ ឱ្យបានល្អរួមចំណែកដល់ការកំសាន្តរបស់ភ្ញៀវទេសចរ និងកសាងសោភ័ណភាពដល់ទីក្រុងសៀមរាបអង្គរផងដែរ ។ ប៉ុន្តែដោយរាជរដ្ឋា

ភិបាលមានបន្ទុកធ្ងន់ធ្ងរជាច្រើន ដែលត្រូវរែកពន់ លទ្ធភាពថវិកានៅមានកំរិត ពុំអាចដោះស្រាយសំណូមពរ នៃការអភិវឌ្ឍន៍លើគ្រប់វិស័យបានតែក្នុងមួយរយៈពេលខ្លីនោះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមអំពាវនាវដល់ ព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ បងប្អូនអាជីវករ ពាណិជ្ជករ សេវាករ បងប្អូនប្រជាពលរដ្ឋទាំងអស់នៅក្នុងខេត្ត សៀមរាប មេត្តាចូលរួមវិភាគទានតាមសទ្ធាជ្រះថ្លា ក្នុងការស្តារ និងកសាងដងស្ទឹងសៀមរាបនេះ ឱ្យបានច្រើនកុះករ និងសូមជួយថែរក្សាអនាម័យបរិស្ថាន តាមដងស្ទឹងឱ្យបានល្អ ។

ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណជាអនេកចំពោះបងប្អូនអាជីវករ សេវាករ ពាណិជ្ជករ ដែលជាម្ចាស់សណ្ឋាគារ ក្រុមហ៊ុនអាកាសចរ ដែលបានចូលរួមវិភាគទានដ៏ថ្លៃថ្លា តាមការអំពាវនាវរបស់រាជរដ្ឋាភិបាលកាលពីថ្ងៃទី ២៧ កុម្ភៈ ឆ្នាំ២០០២ កន្លងមកថ្មីៗនេះ ។

ជាថ្មីម្តងទៀត តាងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងសូមសំដែងនូវសេចក្តីសង្ឃឹមជឿជាក់ដ៏ស្មោះសបំផុតចំពោះព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ បងប្អូនអាជីវករ សេវាករ និងពាណិជ្ជករ ប្រជាពលរដ្ឋយើងទាំងអស់ និងសូមប្រគេនពរ និងជូនពរ សូមបានប្រកបដោយសុខភាពល្អ និងជោគជ័យគ្រប់ប្រការ ។

*-គ្រប់វិភាគទានទាំងអស់ សូមមេត្តាទាក់ទងជាមួយលេខាធិការដ្ឋានរបស់គណៈកម្មការស្តារ និងអភិវឌ្ឍន៍កំណាត់ដងស្ទឹងនេះ ដែលមាន ឯកឧត្តម អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាន តាមទូរស័ព្ទលេខ ០១២ ៨០៨២៥៤, ០១២ ៩៩៨៩៩៨ គ្រប់ពេលវេលា ។*

***សូមអរព្រះគុណ និងសូមអរគុណ !***

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៣ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន